# សម្ភាសន៍ជាមួយឈ្មោះ ទឹម ប៊ុនថូ ភេទប្រុស អាយុ៦៨ឆ្នាំ

មុខងារជំនាន់ខ្មែរក្រហម“ យោធា”

មុខងារបច្ចុប្បន្ន“កសិករ”

ស្រុកកំណើតនៅភូមិតាពេង ឃុំស្អាង ស្រុកស្អាង ខេត្តកណ្តាល

រស់នៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៥៣:៤៩

១៨ទំព័រ

វណ្ណៈ ចឹងជាដំបូងខ្ញុំសូមណែនាំខ្លួនថា ខ្ញុំឈ្មោះសុខ វណ្ណៈមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំមកនេះចង់សរសេរជាសៀវភៅមួយទាក់ទងនិងស្រុកម៉ាឡៃ និងចង់ដឹងប្រវត្តិទឹកដីម៉ាឡៃពីមុនមកនិងចង់ដឹងប្រវត្តិផ្ទាល់ខ្លួនរបស់ពូខ្លះ កាលពីតូចពូមានបានរៀនសូត្រដល់ត្រឹមណាមានធ្លាប់បួសរៀនដែលឬទេ? ចឹងខ្ញុំចង់ដឹងរឿងរ៉ាវរបស់ពូថារៀបការឆ្នាំ៧៧មានប៉ុន្មានគូរអីហ្នឹង ហើយមកក្រោយសម័យ៧៩មានការតស៊ូរៃជាមួយយួនយ៉ាងម៉េចខ្លះ?

ប៊ុនថូៈ បាទ ។

វណ្ណៈ ដើម្បីចងក្រងជាសៀវភៅមួយពីស្រុកម៉ាឡៃ ចឹងពត៌មានទាំងអស់ដែលខ្ញុំបានសម្ភាសន៍ជាពូ តើអនុញ្ញាតឲ្យខាងខ្ញុំយកទៅសរសេរជាសៀវភៅបានទេ?

ប៊ុនថូៈ មានអី ។

វណ្ណៈ ចឹងអត់អីទេ?

ប៊ុនថូៈ បាទ ។

វណ្ណៈ ចឹងខ្ញុំចង់ស្គាល់ឈ្មោះពូ?

ប៊ុនថូៈ ទឹម ប៊ុនថូ ។

វណ្ណៈ អាយុប៉ុន្មាន?

ប៊ុនថូៈ អាយុ៦៨ឆ្នាំ

វណ្ណៈ ប្រពន្ធពូឈ្មោះអី?

ប៊ុនថូៈ សុខ ណា ។

វណ្ណៈ  អាយុប៉ុន្មាន?

ប៊ុនថូៈ  ៥៧ឆ្នាំ ។

វណ្ណៈ  មានកូនចៅប៉ុន្មាន?

ប៊ុនថូៈ  មានកូន៧នាក់ ។

វណ្ណៈ  ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ប៊ុនថូៈ  ស្រី៣ប្រុស៤ ។

វណ្ណៈ  ពូមានស្រុកកំណើតនៅណា?

ប៊ុនថូៈ  នៅស្អាង ។

វណ្ណៈ  នៅភូមិអី?

ប៊ុនថូៈ  ភូមិតារោង ឃុំស្អាង ស្រុកស្អាង ខេត្តកណ្តាល ។

វណ្ណៈ  ចឹងបច្ចុប្បន្ននៅភូមិណា?

ប៊ុនថូៈ  នៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

វណ្ណៈ  សព្វថ្ងៃប្រកបមុខរបរអីដែរ?

ប៊ុនថូៈ  កាលកំ ប៊ុនថូខ្ញុំនៅមានខ្ញុំដុំតែដែកហ្នឹងឯង ឥឡូវឈប់ហើយ ។

វណ្ណៈ  ចឹងមានធ្វើស្រែចំការខ្លះដែរ?

ប៊ុនថូៈ  ធ្វើនៅខាងក្រោយបន្តិចនេះឯង ។

វណ្ណៈ  ចឹងកាលពីនៅតូចៗពូមានបានរៀនសូត្រទេ?

ប៊ុនថូៈ  កាលពីតូចខ្ញុំកូនកំព្រាតាំងពីអាយុ១៣ឆ្នាំ យាយខ្ញុំយកទៅផ្ញើរនិងលោកនៅវត្ត ។

វណ្ណៈ  ចឹងកាលអាយុ១៣ឆ្នាំនៅវត្តណា?

ប៊ុនថូៈ  នៅវត្តស្អាងស្រែ ។

វណ្ណៈ  ចឹងឪពុកពូឈ្មោះអីដែរ?

ប៊ុនថូៈ  ឈ្មោះ ទឹម ថាញ់ ។

វណ្ណៈ  ម្តាយ?

ប៊ុនថូៈ  ថោង គ្រីស ។

វណ្ណៈ  ចឹងគាត់ស្លាប់ជំនាន់ណា?

ប៊ុនថូៈ  ស្លាប់ជំនាន់តា សីហនុនោះ ។

វណ្ណៈ  គាត់ស្លាប់ដោយសារអី?

ប៊ុនថូៈ  ម៉ែខ្ញុំកើតពីស គាត់ស្លាប់បានបីខែឪពុកខ្ញុំស្លាប់ទៀត ។

វណ្ណៈ  ចឹងបងប្អូនមានប៉ុន្មាននាក់?

ប៊ុនថូៈ  បងប្អូនមាន៥ តែសម័យនោះអស់ពីរ ។

វណ្ណៈ  ស្លាប់ជំនាន់ណាពីរនាក់ហ្នឹង?

ប៊ុនថូៈ  ស្លាប់ជំនាន់ប៉ុល  ពត ។

វណ្ណៈ  ចឹងពូធ្លាប់រៀនសូត្រធ្លាប់ឆ្លងកាត់ចឹង  នៅសម័យក្រោយរដ្ឋប្រហាពូធ្វើអីដែរ?

ប៊ុនថូៈ  ខ្ញុំធ្វើនៅកងពិសេស ។

វណ្ណៈ  កងតាណាត.?

ប៊ុនថូៈ នៅជិតគ្នានិងឯងតាំងតា  ណាតហ្នឹងឯង ។

វណ្ណៈ  ចឹងចូលកងពិសេសហ្នឹងនៅឆ្នាំណាឬរដ្ឋប្រហារ ហើយឬក៏ឆ្នាំណា?

ប៊ុនថូៈ  ចូលកាលឆ្នាំ៧៣ហ្នឹង ។

វណ្ណៈ  ចឹងកាល៧៣ហ្នឹងពូយល់ឃើញយ៉ាងម៉េចបានជាពូចូល?

ប៊ុនថូៈ  កាលនោះគេឲ្យធ្វើឈ្លបចេះតែឲ្យទប់ទល់នៅព្រែកតូចហ្នឹង  នៅពេលនេះខ្ញុំនៅគ្រប់គ្រងហ្នឹង ពេលវៃទៅឈ្នះនៅព្រែកតូចហ្នឹងគេអូសយកទៅធ្វើបណ្តោយទៅ ។

វណ្ណៈ  បាទ ។

ប៊ុនថូៈ  កាលហ្នឹងមិនមានចិត្តធ្វើអីអត់ទេ?

វណ្ណៈ  បាទ ។

ប៊ុនថូៈ  កាលហ្នឹងយើងខំការពារប្រជាជននោះវាល្បីទៅគេហៅយកទៅបណ្តោយទៅ ។

វណ្ណៈ  និយាយទៅកាលជំនាន់ហ្នឹងច្រើនចូលព្រៃម៉ាគី?

ប៊ុនថូៈ  ហ្នឹងមុនហ្នឹង  កាលហ្នឹងសម្តេចប្រកាស ។

វណ្ណៈ  ចឹងសម្តេចប្រកាសនៅឆ្នាំណា?

ប៊ុនថូៈ  នៅឆ្នាំ១៩៧០  នៅពេលដែលលោកចេញទៅ  ប្រកាសឲ្យកូនចៅចេញទៅចូលព្រៃម៉ាគីហ្នឹងខ្ញុំ នៅភ្នំពេញឡើយទេ ។

វណ្ណៈ  ចឹងពេល៧៣បានពូចូលទៅភូមិកំណើតបានចូលកងពិសេស?

ប៊ុនថូៈ  បាទ ។

វណ្ណៈ  កងពិសេសហ្នឹងនៅកងពលណា?

ប៊ុនថូៈ  កងពល១១ ។

វណ្ណៈ  កងពល១១ហ្នឹងពីណាគ្រប់គ្រងតាណាតឬតាពីន?

ប៊ុនថូៈ  តាពីន  មិនមែនទេ  តាណាតនិងតាពីនកងពល១២ ។

វណ្ណៈ   កងពល១១?

ប៊ុនថូៈ   កងពល១១  សោមហ្នឹងហើយ  តែគេរើចោលកាលដែលចូលភ្នំពេញ  ពួកខ្ញុំហ្នឹងវារគាត់រគាយអស់ហើយ ។

វណ្ណៈ   ចឹងពូនៅជាមួយសោមហ្នឹងរយៈពេលប៉ុន្មានឆ្នាំដែរ?

ប៊ុនថូៈ   ខ្ញុំនៅជាមួយបានមួយឆ្នាំ  ខ្ញុំពិការទៅ ។

វណ្ណៈ   ចឹងពូពិការឆ្នាំណា?

ប៊ុនថូៈ   នៅក្នុងឆ្នាំ៧៣ហ្នឹងដែរ ។

វណ្ណៈ   កាលហ្នឹងរើជាមួយទាហានខាងណា?

ប៊ុនថូៈ   កាលរើជាមួយទាហានលន់ នល់ ។

វណ្ណៈ   ចឹងពូអត់នៅជាមួយកងពលតាណាត  តាពីនអីទេ?

ប៊ុនថូៈ   អត់ទេ ។

វណ្ណៈ   ចឹងតា  សោមកាន់មុខព្រួញចូលទីក្រុងភ្នំពេញហ្នឹងតាមច្រកណាវិញ?

ប៊ុនថូៈ   ខាងត្បូងភ្នំពេញតាមទន្លេបាសាក់ហ្នឹង ។

វណ្ណៈ   ចឹងឆ្នាំ៧៣ពូត្រូវរបួសចឹងឈប់ឡើងរើហើយ?

ប៊ុនថូៈ   គេដកឲ្យមកពេទ្យចេញពីពេទ្យទៅកាន់ខាងសេដ្ឋកិច្ចវិញ ។

វណ្ណៈ   ចឹងនៅឆ្នាំ៧៥ខ្មែរក្រហមចូលដល់ភ្នំពេញ?

ប៊ុនថូៈ   បាទ ។

វណ្ណៈ   ចឹងពេលចូលដល់ភ្នំពេញគេឲ្យពូធ្វើខាងអីវិញ?

ប៊ុនថូៈ   ដំបូងគេឲ្យចូលមន្ទីរពិការ ដល់ចេញពីមន្ទីរពិការទៅគេឲ្យធ្វើពេទ្យ ។

វណ្ណៈ   ចឹងធ្វើពេទ្យដល់ឆ្នាំណា?

ប៊ុនថូៈ   តាំងពី៧៦ដល់ឆ្នាំរត់តែម្ដង ។

វណ្ណៈ   ចឹងពូពិការហើយបានពូរៀបការ?

ប៊ុនថូៈ   ឆ្នាំជិតរត់ហើយបានគេចាប់ដុល១ហ្នឹង ។

វណ្ណៈ   នៅឆ្នាំណា?

ប៊ុនថូៈ   ឆ្នាំ៧៧ ។

វណ្ណៈ   ចឹងកាលរៀបជាមួយពូហ្នឹងមានប៉ុន្មានគូរ?

ប៊ុនថូៈ   មាន៤គូរ ។

វណ្ណៈ   ចឹងពូមានបានឃើញមីងមុនទេ?

ប៊ុនថូ៖ កាលហ្នឹងនៅជាមួយគ្នាហ្នឹងឯងប៉ុន្តែមិនកំណត់គូរទេ ។

វណ្ណៈ ចឹងកាលអង្គការចាប់គូរមកពូពេញចិត្តដែរ?

ប៊ុនថូ៖ ពេញចិត្ត ។

វណ្ណៈ ចឹងមីងវិញ?

ប៊ុនថូ៖ មីងមិនដឹងទេ ។“ប្រពន្ធនិយាយថា កាលហ្នឹងមិនពេញចិត្តទេ និយាយប្រាប់ក្មួយឯងឲ្យត្រង់ ព្រោះអីបងខ្ញុំគាត់ការតាំងពីឆ្នាំ១៩៦៨ ដល់ហើយគាត់ទៅនៅខាងម្តាយក្មេក ម្តាយក្មេកធ្វើបាបដេរប្រទេចពេកណាស់ ដល់ហើយខ្ញុំទៅឃើញបងខ្ញុំ ខ្ញុំសច្ចារក្នុងចិត្តអត់យកប្តីមួយជីវិត ខ្ញុំថាស្រុកស្រួលបួលអាយុ៣០ទៅ៤០ខ្ញុំកោសក់ទៅវត្តហើយ ខ្ញុំមិនយកទេប្តីមួយជាតិនេះ អ្នកដណ្តឹងខ្ញុំខ្វះអីបានជាខ្ញុំរត់មកធ្វើបដិវត្តន៍ហ្នឹង ស៊ីចោលជំនូនគេខ្ញុំប្រាប់ក្មួយឯងទៅ អ្នកដណ្តឹងខ្ញុំមិនបេះខ្វះទេ តែខ្ញុំមិនយក ។

វណ្ណៈ ចឹងកាលហ្នឹងមីងអត់ធ្វើការនៅជាមួយគ្នាទេ?

ប៊ុនថូ៖ នៅជាមួយគ្នា ជាពេទ្យដែលតែគាត់ខាងសេដ្ឋកិច្ច ដើររកឧបត្ថម្ភក្នុងមន្ទីរពេទ្យទៅ ។

វណ្ណៈ នៅពេលដែលវៀតណាមវ៉ៃចូលទីក្រុងភ្នំពេញហ្នឹងហេតុអីបានជាពូមីងមិនរត់ទៅស្រុក?

ប៊ុនថូ៖ គេថាយួនយកទៅដាំតែអុង ។

វណ្ណៈ គេប្រាប់ចឹង ។

ប៊ុនថូ៖ បាទ ។

វណ្ណៈ ពីណាជាអ្នកនិយាយចឹង?

ប៊ុនថូ៖ អ្នកនៅកងជាមួយគ្នាហ្នឹងនិយាយតៗគ្នា ខ្ញុំតាំងចិត្តថាមិនរត់ដែលហ្នឹង តែប្តីខ្ញុំថារៀបចំឥវ៉ាន់ទៅ ខ្ញុំឡើងទៅលើឡៅ ខ្ញុំយកគ្រាប់បែកពីរបី ប៊ុនថូដាក់លើឡើងពីណាឡើងមកយកគ្រាប់បែកបោះដាក់ខ្ញុំថាមិនរត់ហើយកាលហ្នឹងខ្ញុំពោះធំអាកូនបងបង្អស់ផង ។

វណ្ណៈ ចឹងដោយសារខ្លាចយួន?

ប៊ុនថូ៖ ខ្លាចយួន ។

វណ្ណៈ ចឹងខ្ញុំសួរទៅពូវិញថា កាលពូធ្វើពេទ្យហ្នឹងពូមានជួបហេតុការណ៍អីខ្លះដែលនៅក្នុងមន្ទីរពេទ្យហ្នឹង?

ប៊ុនថូ៖ ពេទ្យមុនដំបូងនៅពេទ្យព្រះកេតុមាលាក្រោយមកនៅមន្ទីរ៨៩ ។

វណ្ណៈ ចឹងកាលហ្នឹងពីណាជាប្រធានពេទ្យនៅមន្ទីរ៨៩ហ្នឹង?

ប៊ុនថូ៖ ប្រធានពេទ្យដូចជារកកំណត់មិនឃើញទេ គេដោះដូរជាប់ ។

វណ្ណៈ គេដូរយកទៅណា?

ប៊ុនថូៈ មិនដឹងដាយកទៅណា ។

វណ្ណៈ ចឹងពេទ្យនៅព្រះកេតុមាលា?

ប៊ុនថូៈ ពេទ្យនៅព្រះកេតុមាលាមិត្តបាំង ។

វណ្ណៈ ចឹងក្រោយមកបាំងហ្នឹងទៅណា?

ប៊ុនថូៈ គេចាប់បាត់ខ្លួន ចឹងបានថារកកំណត់មិនឃើញចឹង មួយខែពីរខែដក ។

វណ្ណៈ ចឹងមានដឹងថាដកយកទៅណាទេ?

ប៊ុនថូៈ ដកយកទៅរៀនសូត្រ ។

វណ្ណៈ ចឹងដកទៅរៀនសូត្រពូជឿថាពួកហ្នឹងអាចនៅរស់ទេ?

ប៊ុនថូៈ មិនជឿរស់ទេ ។

វណ្ណៈ ចឹងពូកាលហ្នឹងមានដឹងថា មានការសម្លាប់ដែរ?

ប៊ុនថូៈ ដឹង ។

វណ្ណៈ ចឹងកាលហ្នឹងពូមានភ័យទេ?

ប៊ុនថូៈ ភ័យតែកាលហ្នឹងដូចថាយើងនៅក្នុងលបទៅហើយ ។

វណ្ណៈ ចឹងកាលពូជាបុគ្គលិកពេទ្យហ្នឹងការហូបចុកគ្រប់គ្រាន់ដែរ?

ប៊ុនថូៈ អត់អីទេ បុគ្គលិកពេទ្យ ។

វណ្ណៈ ចឹងថ្នាំសង្កូវអីត្រូវបានទទួលពីខាងណាមក?

ប៊ុនថូៈ មានថ្នាំចាស់ ។

វណ្ណៈ ចឹងមានថ្នាំចាស់?

ប៊ុនថូៈ បាទ!មានថ្នាំចាស់កាលដែលយើងវៃចូលនោះ នៅកេតុមាលាមានផ្ទះមួយមានថ្នាំច្រើនណាស់ មានលុងចូលក្នុងដីទៀត តែរឿងហ្នឹងខ្ញុំមិនសូវច្បាស់ទេ ខ្ញុំមកខាងក្រោដោះស្រាយជីវភាពមិនឲ្យគេខ្វះហូបតែប៉ុណ្ណឹងឯង ។

វណ្ណៈ ចឹងបន្លែយើងទៅយកពីខាងណាមក?

ប៊ុនថូៈ យើងទៅយកគ្រប់ភូមិភាគ ទៅទាក់ទងគេចឹងទៅគេឲ្យមួយឡានពីរឡានចឹងមក មានសាច់គោសាច់ជ្រូកចឹងមកទៅណាស់ ។

វណ្ណៈ បាទ ។

ប៊ុនថូៈ យើងគ្រាន់តែនាំដំណឹងឲ្យគេទៅ យើងខ្វះខាតចឹង ។

វណ្ណៈ ចឹងនៅខាងសេដ្ឋកិច្ចចឹងពេលទៅរកបន្លែនិងមានសំបុត្រស្នាមទេ?

ប៊ុនថូៈ អត់ទេ គ្រាន់តែក្នុងនាមយើងទទួលភារកិច្ចហ្នឹង យើងមានច្បាប់មួយសម្រាប់ដោះស្រាយសេដ្ឋកិច្ចចឹងទៅ ។

វណ្ណៈ កាលជំនាន់ខ្មែរក្រហមហ្នឹងខ្ញុំដឹងថាមានការតឹងតែងណាស់ ចឹងពូដើររកបន្លែចឹងមានលិខិតទេ?

ប៊ុនថូៈ មានលិខិតពីលើហ្នឹងតែម្តងដើរជុំវិញប្រទេសតែម្តង ។

វណ្ណៈ លិខិតពីលើហ្នឹងជានរណាគេ?

ប៊ុនថូៈ លិខិតពីមិត្តម៉េតទទួលខាងយន្តហោះកាលជំនាន់ហ្នឹង ។

វណ្ណៈ ចឹងមិត្តម៉េតហ្នឹងគាត់ទទួលខាងអីទៅ?

ប៊ុនថូៈ គាត់កាន់កាប់ខាងព្រលានយន្តហោះ ។

វណ្ណៈ ចឹងកាលហ្នឹងអ្នកជំនឹមកពីខាងណាជាកម្មាភិបាលនៅក្នុងរោងចក្រហ្នឹងឬខាងប្រជាជនដែរ?

ប៊ុនថូៈ អត់ទេ ខាងកងទ័ព ព្រោះពេទ្យនេះគេហៅពេទ្យអគ្គសេនាធិការ ។

វណ្ណៈ ចឹងព្យាបាលផ្នែកកងទ័ព?

ប៊ុនថូៈ បាទ ។

វណ្ណៈ ចឹងកងទ័ពហ្នឹងមានជំងឺអីខ្លះ?

ប៊ុនថូៈ មានច្រើនប្រភេទមានគ្រុនចាញ់និងរបួស ។

វណ្ណៈ មានស្លាប់ទេមកដល់ពេទ្យ?

ប៊ុនថូៈ មានអ្នកណាដែលជួយមិនបានស្លាប់ទៅ ។

វណ្ណៈ ចឹងកាលហ្នឹងមានស្លាប់ច្រើនដែរ?

ប៊ុនថូៈ ស្លាប់មិនសូវច្រើនទេ ។

វណ្ណៈ ស្លាប់ដោយខ្វះថ្នាំព្យាបាលឬយ៉ាងម៉េច?

ប៊ុនថូៈ អត់ទេ ដូចថាផ្លូវឆ្ងាយមានមេរោគវាចូល ។

វណ្ណៈ ចឹងកាលហ្នឹងមានរបួសច្រើននៅឆ្នាំណា?

ប៊ុនថូៈ ឆ្នាំ៧៧ហ្នឹងតែម្តង ។

វណ្ណៈ ចឹងឆ្នាំ៧៧-៧៨វៃជាមួយយួនហើយ?

ប៊ុនថូៈ វៃជាមួយយួននៅរតនៈគិរីនិងមណ្ឌលគិរីហើយខាងប្រៃវែងនេះ ។

វណ្ណៈ ចឹងក្រៅពីទាហានអត់មានព្យាបាលទេ?

ប៊ុនថូៈ អត់ទេ ។

វណ្ណៈ ចឹងកាលហ្នឹងមានបុគ្គលិកពេទ្យមានបាត់ខ្លួនទេ?

ប៊ុនថូៈ មាន ។

វណ្ណៈ   ចឹងមានឃើញជនជាតិចិនមកបម្រើនផ្នែកពេទ្យទេ?

ប៊ុនថូៈ  អត់ទេ តែខាងគេមានខាងមន្ទីរពិសោធន៍ ។

វណ្ណៈ   ចឹងកាលជំនាន់ខ្មែរក្រហមនៅពេទ្យចឹងអាចដើរទៅណាមកណាបានទេ?

ប៊ុនថូៈ  អត់ទេ និយាយទៅបានតែខ្ញុំមួយទេ ។

វណ្ណៈ   ចឹងពូនៅខាងសេដ្ឋកិច្ចដើរបាន?

ប៊ុនថូៈ  នៅក្នុងមន្ទីរពេទ្យហ្នឹងដើរបានតែពីរនាក់ទេ ឡានមួយហ្នឹង ។

វណ្ណៈ   ចឹងពូបេះបើកឡានទេ?

ប៊ុនថូៈ  ខ្ញុំបេះ ។

វណ្ណៈ   ចឹងម្នាក់ទៀតបេះបើឡានទេ?

ប៊ុនថូៈ  បេះដូចគ្នា ។

វណ្ណៈ   ចឹងម្នាក់ទៀតគាត់នៅរស់ដែរ?

ប៊ុនថូៈ  នៅទន្លេបាទីនោះ ។

វណ្ណៈ   បើកឡានកាលហ្នឹងមានភ័យទេ?

ប៊ុនថូៈ  ដូចជាមិនអីទេ តែកាលហ្នឹងគេកំណត់ល្បឿនឲ្យតែ៣០ យើងបើកតែ៣០ ទៅណាស់ ។

វណ្ណៈ   ឡានម៉ាក់អីគេ?

ប៊ុនថូៈ  ឡានអាមេរិកហ្នឹង ឡានទាហានហ្នឹង ឡានចិន អាឡានកាកសំណល់ឡានបារាំង ។

វណ្ណៈ   ចឹងដឹកបន្លែអីមានដែលជិះកាត់តាមមុខវាំងអីទេ?

ប៊ុនថូៈ  ជិះកាត់ទាំងអស់ហ្នឹង ។

វណ្ណៈ   ចឹងខ្ញុំនិយាយដល់៧៩ កាលពូរត់ហ្នឹងធ្វើដំណើរតាមរបៀបណា?

ប៊ុនថូៈ  ខ្ញុំកាលរត់ហ្នឹងពីដំបូងបានម៉ូតូដល់បាញ់ខ្លាំងទៅដើរដោយជើងផ្ទាល់រត់ចូលព្រៃផ្ទាល់តែម្តង ។

វណ្ណៈ   ចឹងជិះម៉ូតូចេញពីភ្នំពេញកាត់តាមណាខ្លះ?

ប៊ុនថូៈ  ជិះតាមផ្លូវជាលេខ៤ ហើយចេញមកតាមខន្ធុងវិញ ។

វណ្ណៈ   ចឹងកាលហ្នឹងដើរវិញអត់មានឡានជិះទេ?

ប៊ុនថូៈ  អត់ទេ ។

វណ្ណៈ   ចឹងនៅពេលរត់មានបាននាំមីងមកជាមួយទេ?

ប៊ុនថូៈ  អត់ទេ ខ្ញុំដឹកយកមកដាក់រេភ្លើងពេលរថភ្លើងអត់ចេញទៅ ខ្ញុំរត់ផ្សេងគាត់ផ្សេង ។

វណ្ណៈ   កាលហ្នឹងមានកូននៅ?

ប៊ុនថូៈ  កាលហ្នឹងពោះធំ ។

វណ្ណៈ  ចឹងប្រពន្ធពូពោះធំចឹងនៅពេលរត់បែកគ្នាចឹង  ពូមានអារម្មណ៍យ៉ាងម៉េច?

ប៊ុនថូៈ  មានចេះតែមានហើយតែមិនដឹងជាទាក់ទងយ៉ាងម៉េច  ហើយខ្ញុំជួយដោះស្រាយនេះផង ។

វណ្ណៈ  ចឹងមីងមានអារម្មណ៍យ៉ាងម៉េចដែលនៅពេលបែកជាមួយពូចឹង?

ប៊ុនថូៈ  ប្រពន្ធគាត់និយាយ«មានអារម្មណ៍យ៉ាងម៉េចអត្តុយយំ»

វណ្ណៈ  កាលហ្នឹងពោះធំប៉ុន្មានខែ?

ប៊ុនថូៈ  ៨ខែ?

វណ្ណៈ  ជិតកើតហើយ?

ប៊ុនថូៈ  កើតនៅសត្តមយើងក្រោមដើមគរ ។

វណ្ណៈ  មានពេទ្យទេ?

ប៊ុនថូៈ  មានពេទ្យឆ្មបរត់មកជាមួយគ្នា ។

វណ្ណៈ  ចឹងកាលហ្នឹងពូរត់បានប៉ុន្មានខែប៉ុន្មានថ្ងៃបានមកដល់ជាយដែន?

ប៊ុនថូៈ  ខ្ញុំមិនបានគិតរឿងហ្នឹងដែរ  តែតាមស្មានប្រហែលជាបីខែ ។

វណ្ណៈ  ចឹងទំរាំមកដល់ម៉ាឡៃនេះប្រហែលជាខែប៉ុន្មាន?

ប៊ុនថូៈ  ដូចជាខែចូលឆ្នាំនៅភ្នំម៉ាឡៃនេះ ។

វណ្ណៈ  ចឹងមកដល់ម៉ាឡៃហ្នឹងមានខែ៨?

ប៊ុនថូៈ  បាទ!  កាលហ្នឹងមានដើរមករហូតឯណាយើងស្នាក់នៅចឹងមានគេដេញរត់ទេ  ជួនកាលរត់ទៅ
ក្រោយវិញទៀត ។

វណ្ណៈ  ចឹងមកតាមផ្លូវហ្នឹងមានអាហារហូបចុកគ្រប់គ្រាន់ទេ?

ប៊ុនថូៈ  មានខ្លះអត់ខ្លះចឹងទៅ  ជួនកាលយើងឃើញជង្រុកចឹងទៅយើងយកស្ពាយចឹងទៅ  ពេលគេដេញ
បាញ់ចឹងទៅទម្លាក់ចោលខ្លះទៅ ។

វណ្ណៈ  ចឹងមានហ៊ានដើរតាមថ្នល់ជាតិទេឬតាមព្រៃ?

ប៊ុនថូៈ  មានដើរខ្លះដែរ  តាមព្រៃខ្លះដែរ  តាមព្រៃភាគច្រើន ។

វណ្ណៈ  ចឹងនៅតាមផ្លូវមានឃើញសកម្មភាពអីខ្លះ  ពូមានឃើញមនុស្សស្លាប់តាមផ្លូវឬមួយយ៉ាងម៉េច
ដែរ?

ប៊ុនថូៈ  ខ្ញុំដូចជាមិនសូវជួបដែរ  តែមកដល់បរិលយើងនេះបានឃើញមនុស្សគេវៃចោលតាមស្រះមួយ
តែគេវៃចោលពីមុនមក ។

វណ្ណៈ  ចឹងឃើញមនុស្សស្លាប់តាមស្រះ?

ប៊ុនថូៈ  ហ្នឹងហើយ ។

វណ្ណៈ ចឹងមិនមែនឃើញមនុស្សស្លាប់ដោយសាររត់តាមផ្លូវទេ?

ប៊ុនថូៈ ហ្នឹងហើយខ្ញុំទៅយកស្រូវនៅជង្រុកហ្នឹង ស្រាប់តែនៅក្រោយជង្រុកហ្នឹងឃើញខ្មោចនណែល ហ្នឹងស្អុយហើយ ដល់ខ្ញុំស្រាវជ្រាវសួរគេទៅ គេថាជំនាន់យួនចូលដំបូង តែពីណាជាអ្នកវៃចោលខ្ញុំមិនបានដឹងទេ ។

វណ្ណៈ ចឹងមិនដឹងពីណាវៃចោលដែរ?

ប៊ុនថូៈ សូម្បីតែខ្ញុំឲ្យតែពាក់ក្រមាខុសគ្នាហ្នឹងក៏គេតាមវៃចោលដែរ?

វណ្ណៈ ម៉េចចឹង?

ប៊ុនថូៈ គេថាក្រមាសខ្មៅខាងនិរតី ខាងបូព៌ា កាលហ្នឹងគេចតែគ្នាឯងទៅវិញទៅមកហ្នឹង ។

វណ្ណៈ ចឹងមានគេចគ្នាឯងទៀត?

ប៊ុនថូៈ កាលនៅជុំគ្នាជាមិត្តទេ នរណាធ្លាប់សម្លាប់គេ គេដឹងហេតុផលគេតាមសម្លាប់ ។

វណ្ណៈ ចឹងយើងមិនដឹងក្រមាមួយណាយើងចេះតែប្រើ?

ប៊ុនថូៈ គេសួរយើង តែដល់ពេលនេះគេលបប្រាប់យើង គេថាក្រមានេះក្រមាពួកនិរតីគេស្អប់ពួកហ្នឹងណាស់ ។

វណ្ណៈ ចឹង?

ប៊ុនថូៈ គេថាពួកតាម៉ុក ប្រជាជនជាអ្នកស្អប់នោះ ។

វណ្ណៈ ចឹងមិនមែនខ្មែរក្រហមគ្នាឯងទេ ប្រជាជនទេ?

ប៊ុនថូៈ ប្រជាជន ចំណាំក្រហម ចុះកាលដែលធ្វើបាបគាត់ក្រមាហ្នឹងឯង ។

វណ្ណៈ ចឹងកាលហ្នឹងមានស្លាប់ច្រើនដែរ?

ប៊ុនថូៈ ចាស!ប្រពន្ធគាត់និយាយ "ចឹងខ្ញុំកាលហ្នឹងគេនាំខ្ញុំយកទៅវៃចោល តែអ្នកស្រុកគេអាណិតឃើញយើងពោះធំនោះ គាត់ថាមកណេះក្លួយកាលហ្នឹងដើរដាច់បាយមួយអាទិត្យចូលសុំសហករណ៍គាត់ហូប កាលហ្នឹងនៅមានសហករណ៍ ។

វណ្ណៈ ៧៩ហ្នឹង?

ប៊ុនថូៈ ចាស! គាត់ថាមកតាមអីកូន មកតាមគាត់ប្រហែលជា២០នាក់ដាងចេះតែជ្រៅទៅៗ ហើយបានមីប្អូនមួយវាធ្លាប់នៅស្រុកហ្នឹងនោះ វាថាបងហ្នឹងសុទ្ធព្រៃខ្មោចគេនាំយើងវៃចោលហើយ ។

វណ្ណៈ ប្រជាជនហ្នឹង?

ប៊ុនថូៈ ប្រជាជនហ្នឹងណាស់ ។

វណ្ណៈ ចឹងខ្ញុំមិនដែលឮទេរឿងហ្នឹង កាលហ្នឹងខ្ញុំបានដឹងថាប្រជាជនមានកំហឹងនៅក្នុងពេលហ្នឹងរត់រួមមិនរួចអីមានស្លាប់នៅពេលហ្នឹងតែម្តង ។

ប៊ុនថូៈ ខ្ញុំពិបាកជិតមួយខែអីនោះ ខ្ញុំមកដល់ជ្រាវខ្ញុំមានឡានវិញហើយ ។

វណ្ណៈ ចឹងមកដល់ជ្រាវមកដល់ម៉ាឡៃនេះយើងចូលព្រៃហើយ ចឹងកំ ប៊ុនថូខ្មែរក្រហមប្រមូលបានពេលណានៅពេលភ្លាមៗដែរ?

ប៊ុនថូៈ អត់ទាន់បានភ្លាមៗគ្រាន់តែនៅតាមព្រំដែនហ្នឹងទៅមិនទាន់ផ្តុំបានទេ អ្នកនៅគុំគ្នានៅគុំហ្នឹងឯង ក្រោយមកបានរៀបកំ ប៊ុនថូជាឈ្លបចឹងទៅ ។

វណ្ណៈ ចឹងយើងស្គាល់កំ ប៊ុនថូគ្នាច្បាស់នៅឆ្នាំណាដែរ?

ប៊ុនថូៈ មួយឆ្នាំ ។

វណ្ណៈ ចឹងនៅឆ្នាំ៨០ស្គាល់កំ ប៊ុនថូគ្នាច្បាស់ហើយ?

ប៊ុនថូៈ បាទ ។

វណ្ណៈ ចឹងនៅឆ្នាំ៨០មានប្រធានវរៈមានប្រធានកងពលអីហើយ?

ប៊ុនថូៈ មាន ។

វណ្ណៈ ចឹងពូកាលហ្នឹងនៅក្នុងកងពលអីដែរ?

ប៊ុនថូៈ ខ្ញុំលាក់ខ្លួនរហូតខ្ញុំអូក៏ខ្ញុំមិនធ្វើដែរ ។

វណ្ណៈ ចឹងមកដល់ក្នុងព្រៃនេះលែងធ្វើហើយ?

ប៊ុនថូៈ ចេញពីភ្នំពេញមកនេះលាក់ខ្លួនបណ្តោយ ។

វណ្ណៈ ចឹងមកដល់ជំរុំនេះ គេត្រូវការកំ ប៊ុនថូវៃជាមួយយួនវិញនោះ?

ប៊ុនថូៈ គេត្រូវការទប់ទល់ជាមួយយួនហ្នឹងឯងតែគេមិនបានទៅទប់ទល់ធំដុំទេ ព្រោះគ្មានបាយស៊ីប៉ុន្មានផងនោះ គ្រាន់តែទៅបាញ់យកតែស្បៀងចឹងទៅរត់មកវិញ ។

វណ្ណៈ ចឹងកាលហ្នឹងយ៉ាងម៉េចបានជាពូមិនបានទៅឬមួយពូចាស់?

ប៊ុនថូៈ ខ្ញុំចាស់ផង ណាមួយខ្ញុំលាក់ការណ៍មិនឲ្យគេដឹងថាខ្ញុំធ្វើស្អីៗ ។

វណ្ណៈ ចឹងនៅខាងនេះគេអត់មានបន្ទំយើងទេ បើយើងមិនចង់ទៅក៏បាន?

ប៊ុនថូៈ លែងបន្ទំហើយ ។

វណ្ណៈ ចឹងកាលហ្នឹងពូនៅម៉ាឡៃហ្នឹងឬនៅជុំរំឯនោះ?

ប៊ុនថូៈ ខ្ញុំនៅតាមជួរព្រំដែនហ្នឹងរហូត អត់មាននៅជុំរំទេ ហើយយាយទេដែលដាច់បាយអីនោះ បានគេប្រមូលទៅជុំរំស្រះកែវនោះ ។

វណ្ណៈ ចឹងពូនៅក្នុងព្រៃជាមួយទ័ពខ្មែរក្រហមចឹងទៅ?

ប៊ុនថូៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងក្មេងៗឡើងវៃទៅ?

ប៊ុនថូៈ ក្មេងៗឡើងវិញទៅ ខ្ញុំនៅជាំបាយឲ្យគេទៅ ។

វណ្ណៈ ចឹងពីណាជាអ្នកគ្រប់គ្រងនៅហ្នឹង?

ប៊ុនថូៈ កាលហ្នឹងមានតា ហុង មានតា ជាម លោកសុខ ភាព ។

វណ្ណៈ ចឹងកាលហ្នឹងលោកតា អៀង សារី តា ប៉ុល ពតនៅហ្នឹងដែរ?

ប៊ុនថូៈ មិនដែលឃើញគាត់ទេ មិនដឹងជាគាត់នៅណា ។

វណ្ណៈ ចឹងក្រោយមកបានគាត់មក?

ប៊ុនថូៈ គាត់មក តែមកតែមួយភ្លែតៗទេ ។

វណ្ណៈ ចឹងផ្ទះគាត់នេះ?

ប៊ុនថូៈ ផ្ទះហ្នឹងជាការិយាល័យសម្រាប់ធ្វើការ ។

វណ្ណៈ ចឹងលោកអៀង សារីមិនមែននៅនេះទេ?

ប៊ុនថូៈ អត់ទេ គាត់មកតែមួយភ្លែតៗហ្នឹងណាស់ ខាងម៉ាឡៃការិយាល័យហ្នឹងមួយទៅខាងសង្កាការិយាល័យមួយទៅ តែគ្រាន់តែឈ្មោះអ្នកនេះអ្នកនោះតែមិនដែលនៅហ្នឹងទេ ។

វណ្ណៈ ចឹងមិនហ៊ាននៅយូរទេ?

ប៊ុនថូៈ ឲ្យតែធ្វើការចប់ទៅវិញបាត់ហើយ ។

វណ្ណៈ ចឹងកាលហ្នឹងយើងអត់ទៅជួយវៃគេចឹង គេឲ្យបាយទឹកយើងហូបដែរ?

ប៊ុនថូៈ អត់អីទេ ។

វណ្ណៈ ចឹងកាលហ្នឹងមានតែព្រៃមានដើមឈើធំយើងធ្វើជំរកយ៉ាងម៉េចទៅ?

ប៊ុនថូៈ កាលហ្នឹងយើងចេះតែកាប់ឈើធ្វើដំបូងមានកៅស៊ូមួយផ្ទាំងម្នាក់ចឹងទៅ តែកង់ទ័ពមិនសូវនេះប៉ុន្មានទេ វាខ្លាំងប្រជាជននោះ ។

វណ្ណៈ ប្រជាជនយ៉ាងម៉េច?

ប៊ុនថូៈ ប្រជាជនមិនអាចប្រជាជនប្រើប្រាស់បានទេ មានកូនមានអីសព្វបែបយ៉ាង ។

វណ្ណៈ ចឹងមានប្រជាជនស្លាប់ដោយសារគ្រុនចាញ់មានទេ?

ប៊ុនថូៈ មាន ប្រជាជនហ្នឹងក៏មិនមែនប្រជាជនចំដែរ ប្រជាជនជាកង់ទ័ពហ្នឹងដែលហ្នឹង ប្រជាជនតែប្រពន្ធកូនប្តីជាអ្នកកាន់កាំភ្លើងដដែរ ។

វណ្ណៈ ចឹងកាលហ្នឹងមានវៀតណាមវៃចូលមកជិតហ្នឹងទេ?

ប៊ុនថូៈ វៀតណាមអាចវៃចូលមកគៀកហ្នឹងដែរ តែខ្ញុំមិនបានវៃជាមួយគេទេ ។

វណ្ណៈ ចឹងម៉ាឡៃហ្នឹងមានព្រៃឈើធំៗច្រើន?

ប៊ុនថូៈ នៅហ្នឹងព្រៃឈើទាំងអស់ហ្នឹង ប៉ុន្តែកាលហ្នឹងគេចាប់ផ្ដើមរៀបហើយណាស់ កងទ័ពរៀបហើយ គេចាប់រៀបឲ្យមានប្រជាជន អ្នកណាមិនចង់ធ្វើកងទ័ពអីមកធ្វើប្រជាជនទៅ ។

វណ្ណៈ ចឹងកាលហ្នឹងដើមឈើហ្នឹង?

ប៊ុនថូៈ ដើមឈើហ្នឹងកាប់ធ្វើចំការ ។

វណ្ណៈ ចឹងដើមឈើធំៗកាប់យកទៅណា?

ប៊ុនថូៈ កាលហ្នឹងរំលំចោលដុតឆេះអស់ទៅ ។

វណ្ណៈ ចឹងអត់មានកាប់ឈើលក់ឲ្យថៃទេ?

ប៊ុនថូៈ លក់ឲ្យថៃក្រោយមកទៀតទេ ខ្លះមិនចង់ធ្វើប្រជាជនទេ ខ្លាចមិនរស់នោះមិនធ្លាប់ណាស់ ។

វណ្ណៈ បាទ ។

ប៊ុនថូៈ ចេះតែប្រកែកគេប្រជុំថាណរណាចង់ធ្វើប្រជាជនខ្លះ ខ្លះភ័យដល់នៅយូរៗទៅគេចែករណាដើរ លក់ឲ្យថៃនោះបានលុយ ។

វណ្ណៈ បាទ ។

ប៊ុនថូៈ ដល់បានលុយទៅបានជាកងទ័ពនោះរត់មកធ្វើប្រជាជនភាគច្រើនបណ្ដោយ ។

វណ្ណៈ ចឹងកាលហ្នឹងពីណាជាអ្នកប្រកាសឲ្យធ្វើប្រជាជនហើយយើងមិនហ៊ាន?

ប៊ុនថូៈ ខាងលើហ្នឹងហើយ ។

វណ្ណៈ ចឹងប្រកាសឲ្យធ្វើប្រជាជនចង់ភ័យ?

ប៊ុនថូៈ បាទ!ដល់ធ្វើប្រជាជនកាប់ឈើបានលុយ ដល់ធ្វើកងទ័ពមានលុយឯណាដល់ចឹងកងទ័ពរត់មកធ្វើ ប្រជាជនដែរ ។

វណ្ណៈ ឆ្នាំណា?

ប៊ុនថូៈ អាហ្នឹងបន្ទាប់គ្នាមួយឆ្នាំមកហ្នឹង ។

វណ្ណៈ ចឹងឆ្នាំ៨០-៨១នៅព្រៃស្អុកនៅឡើយ?

ប៊ុនថូៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងដល់ពេលក្រោយទៀតប្រកាស់ឲ្យប្រជាជនកាប់ឈើ?

ប៊ុនថូៈ ប្រកាសតែម្ដងទេ ចេះតែរុករៀនហើយ ដួនកាលកាប់ចំការបានធ្វើពេលយួនដេញរត់ទៀតទៅ ដីហ្នឹងដូរម្ចាស់ទៀតទៅ ដល់ពេលជិតចប់ហើយទើបដឹងថានៅពិត ។

វណ្ណៈ ចឹងនិយាយទៅឈើហ្នឹងអស់ពិតប្រាកដនៅឆ្នាំណា?

ប៊ុនថូៈ មិនដឹងជាឆ្នាំណា ។

វណ្ណៈ សមាហរណកម្មហើយ?

ប៊ុនថូៈ  អស់មុនហ្នឹង ។

វណ្ណៈ  មុនឆ្ងាយប៉ុណ្ណឹងម៉េច?

ប៊ុនថូៈ  មុនប្រហែលជាពីរបីឆ្នាំហ្នឹង ដីចំការហ្នឹងបើទុកឈើចិញ្ចឹមជីវិត តែដុតចោលអស់ព្រោះចង់បានដីធ្វើចំការ ។

វណ្ណៈ  ចឹងគេថានៅម៉ាឡៃហ្នឹងជាចំការមីន?

ប៊ុនថូៈ  ចំការមីនមានដុះខ្លះដាច់ដៃដើងចឹងទៅ ស្លាប់ខ្លះទៅ តែធ្លាប់ធ្វើទ័ពចឹងហើយដែលចេះខ្លាចអី អាណាងាប់ៗទៅ អាណានៅរស់ចេះតែដើរកាប់ទៀតទៅ ។

វណ្ណៈ  ចឹងមីនកាលហ្នឹងពីណាជាអ្នកដាក់?

ប៊ុនថូៈ  ដាក់ទាំងសងខាងហ្នឹងឯង គេដេញយើងចឹងទៅ យើងរត់គេដាក់ទៅដល់យើងដេញគេវិញដាក់វិញទៅ ។

វណ្ណៈ  ចឹងនៅពេលដែលកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជាទៅ កាលហ្នឹងនៅវៃខ្លាំងដែរឬវៃខ្សោយហើយ?

ប៊ុនថូៈ  វៃខ្លាំងតែវៃហ្នឹងវៃអត់មានសម្លាប់គ្នាទេ វៃឲ្យដំណឹងដូចថាគេមកហើយយើងដកទៅ យើងមានទិសដៅវៃយួននោះទេ បើសិនជាសម្លាប់គ្នាឯងងាប់អស់ហើយ តែបើយួនមកតាមណាឲ្យដំណឹងយើង ។

វណ្ណៈ  ចឹងគោលដៅវៃយួន?

ប៊ុនថូៈ  បាទ ។

វណ្ណៈ  ចឹងនៅពេលសម្តេចយាងមកផ្តល់សារតាំងនៅម៉ាឡៃហ្នឹងពូមានបានដឹងទេ?

ប៊ុនថូៈ  បានដឹងតែមិនដឹងជាថ្ងៃប៉ុន្មាន វាមិនបានចាំ ។

វណ្ណៈ  ឥឡូវដូចជាវៀតណាមវៃចូលស្រុកខ្មែរនៅឆ្នាំ៧៩ណាស់ ។

ប៊ុនថូៈ  បាទ ។

វណ្ណៈ  ចឹងបានរយៈពេលប៉ុន្មានឆ្នាំបានសម្តេចយាងចូលមក?

ប៊ុនថូៈ  ប្រហែលជាពីរឆ្នាំ ។

វណ្ណៈ  កាលហ្នឹងទទួលសារតាំងជាមួយពីណាវិញ?

ប៊ុនថូៈ  ទទួលជាមួយមេៗហ្នឹង យើងនេះគ្រាន់តែគេឲ្យការពារខាងក្រៅនេះឯង ។

វណ្ណៈ  ចឹងកាលហ្នឹងពូមានបានចូលទៅជិតទេ?

ប៊ុនថូៈ  មិនបានចូលជិតទេ នៅត្រៀមការពារ ។

វណ្ណៈ  ចឹងសម្តេចយាងមកប៉ុន្មានថ្ងៃដែរ?

ប៊ុនថូៈ  គាត់មកតែមួយភ្លេតៗទេ ។

វណ្ណៈ  ចឹងគាត់ជិះអីមកទៅ?

ប៊ុនថូៈ  មិនបានដឹង  ព្រោះនៅខាងក្រៅមិនបានឃើញផង ។

វណ្ណៈ  ចឹងពូអត់មានបានដឹងថាមានជនជាតិអីមកជាមួយគាត់ខ្លះទេ?

ប៊ុនថូៈ  អត់ដឹង  ទាល់តែអ្នកនៅក្រសួងមន្ទីរនោះ  នៅជាប់អ្នកធំៗហ្នឹងបានគេដឹង ។

វណ្ណៈ  ចឹងកាលហ្នឹងមានអ្នកការពារវឹងមាំដែលអត់មានខាងវៀតណាមចូលមកវ៉ៃទេ?

ប៊ុនថូៈ  អត់មានទេ ។

វណ្ណៈ  ចឹងមុនហ្នឹងមកមានគេរៀបចំហើយ?

ប៊ុនថូៈ  បាទ ។

វណ្ណៈ  ចឹងបងប្អូនពីរនាក់ដែលស្លាប់នោះគាត់ជាប្រជាជនឬមួយជាយោធាដែរ?

ប៊ុនថូៈ  មួយជាប្រជាជនមួយជាយោធា ។

វណ្ណៈ  ចឹងស្លាប់នៅណា?

ប៊ុនថូៈ  មួយស្លាប់នៅកោះគគេចាប់យកទៅ ។

វណ្ណៈ  ប្អូនឬមួយបង?

ប៊ុនថូៈ  ប្អូន ។

វណ្ណៈ  ឈ្មោះអីដែរ?

ប៊ុនថូៈ  ឈ្មោះទឹម  ថុល ។

វណ្ណៈ  មួយទៀត?

ប៊ុនថូៈ  ត្រូវរបួសនៅរតនៈគិរី ។

វណ្ណៈ  ឈ្មោះអី?

ប៊ុនថូៈ  ឈ្មោះ  ទឹម  ថុន ។

វណ្ណៈ  ចឹងស្លាប់នៅរតនៈគិរី?

ប៊ុនថូៈ  ស្លាប់ពេលមកដល់ភ្នំពេញព្រោះមានមេរោគចូល ។

វណ្ណៈ  ចឹងពូមានបានឃើញទេ  ពេលមកដល់ពេទ្យភ្នំពេញ?

ប៊ុនថូៈ  អត់  ខ្ញុំបានដឹងពីយាយខ្ញុំវិញទេ  យាយខ្ញុំគាត់ស្តាប់តាមខ្យល់ទេ  គាត់ក៏មិនស្គាល់ដែរ  កាលហ្នឹងមិនទាន់បានគ្នាណា ។

វណ្ណៈ  ចឹងពូមកដល់ទឹកដីម៉ាឡៃតាំងពីឆ្នាំ១៩៧៩ដល់ឥឡូវឃើញថាទឹកដីម៉ាឡៃមានលក្ខណៈខុសប្លែកគ្នាយ៉ាងម៉េចដែរ?

ប៊ុនថូៈ ខុសខ្លាំងហៅមិនពិតែម្ដង ព្រោះពីមុនមកជាព្រៃរហោឋាន ជាព្រៃខ្លាព្រៃដំរី កាលហ្នឹងមិនហ៊ាន ដើរទេ ។

វណ្ណៈ ចឹងពូមុនមានខ្លាមានដំរី?

ប៊ុនថូៈ មាន ផ្លូវដំរីនៅអូរៗ អាអូរៗហ្នឹងច្រើនតែផ្លូវដំរី មិនថាប្រគុណចែត្រទេឲ្យតែស្រទុំមកដល់ៗ ហាលតែក្រទបកូនមិនស្ងួតដែរ ។

វណ្ណៈ យ៉ាងម៉េចចឹង?

ប៊ុនថូៈ វាអត់មានថៃ ភ្លៀងអត់មានរដូវទេ ។

វណ្ណៈ ហេតុអីទៅ?

ប៊ុនថូៈ ចុះព្រៃគ្របជិតហើយ ។

វណ្ណៈ ចឹងព្រៃមើលមេឃមិនឃើញទេ?

ប៊ុនថូៈ អត់ឃើញទេ ណែនទាំងអស់មើលដើងក្រោមឃើញតែដើមទេ យើងឃើញផ្លែឈើរើសយក មកហូបចឹងតែមិនដឹងជាដើមនៅណាទេ ដើមនៅលើនោះ ។

វណ្ណៈ ចឹងជាព្រៃដំរី?

ប៊ុនថូៈ ហ្នឹងហើយដូចជាដើមម្ទេសចឹង ឃើញតែផ្លែវាជ្រុះមកនិងដីទេ តែដើមវាមិនដឹងទេ ដល់ពេល ស្រាវជ្រាវឃើញទៅដើមវាប៉ុនៗនេះ ។

វណ្ណៈ ម្ទេសហូបផ្លែហ្នឹង?

ប៊ុនថូៈ ហ្នឹងហើយម្ទេសហូបផ្លែហ្នឹង កាលហ្នឹងកាប់ដើមឈើ១០ដើមមិនរលំដល់ដីផង ដើមឈើមាន កំពស់២០ម៉ែតទៅ៣០ម៉ែត្រអីនោះ ។

វណ្ណៈ ចឹងភាគច្រើនដើមឈើអីគេ?

ប៊ុនថូៈ មានចំរុះគ្រប់មុខ ។

វណ្ណៈ មានដើមបេងឈើក្រមអីទេ?

ប៊ុនថូៈ មានដើមបេងមួយៗទេ មានវាចំរុះតែម្ដង ដើមមានអាររធ្វើគ្រឿងផ្ទះបាន ។

វណ្ណៈ ចឹងខ្ញុំនឹងសាកសួរឡើងវិញទៅហ្នឹងរបបខ្មែរក្រហម កាលហ្នឹងពូធ្លាប់ឆ្លងកាត់ចឹង តើពូយល់ថាមាន មនុស្សស្លាប់ច្រើនចឹង ជាកំហុសថ្នាក់លើឬថ្នាក់ក្រោម?

ប៊ុនថូៈ អានេះបើនិយាយឲ្យចំទៅជាកំហុសថ្នាក់ដឹកនាំហើយ ។

វណ្ណៈ ចឹងបើថ្នាក់ដឹងនាំល្អប្រជាជនក៏មិនមានស្លាប់ច្រើនដែរ?

ប៊ុនថូៈ វាមិនដែលមាននរណាដឹកនាំតែពីរបីនាក់បានប្រទេសមួយ អត់មានកាសែតតាមដានកម្មាភិបាល និមួយៗក៏អត់ ហើយដល់ចឹងពួកហ្នឹងវាមានគំនុំខ្វះគុំគ្នាកាលក្មេងៗ ។

វណ្ណៈ   បាទ ។

ប៊ុនថូៈ   ចឹងចេះតែមានគំនុំគុំគ្នាទៅអាពេលហ្នឹងគេឲ្យដឹកនាំហើយ  ម្ចោះហើយចេះតែសម្លាប់គ្នាទៅ ។

វណ្ណៈ   បាទ ។

ប៊ុនថូៈ   ចឹងសួរថាអ្នកដឹកនាំដឹងទេ  មិនមានដឹងទេប្រើសុទ្ធតែពាក្យអង្គការទាំងអស់ហ្នឹង ។

វណ្ណៈ   បាទ ។

ប៊ុនថូៈ   ចឹងខុះចន្លោះត្រង់លហ្នឹងឯង   គំរោងចេញមកហ្នឹងវាស្អាតហើយ   តែធ្វើមិនបានដូចនយោបាយហ្នឹងឯណា  កាលដឹកនាំខាងក្រោមមិនកើត ។

វណ្ណៈ   ចឹងមានន័យថា  កាលហ្នឹងនយោបាយល្អ?

ប៊ុនថូៈ   បាទ ។

វណ្ណៈ   ចឹងមកដល់ឥឡូវហ្នឹងមាននឹកស្រុកកំណើតទេ?

ប៊ុនថូៈ   ដូចជាមិននឹកប៉ុន្មានទេ ។

វណ្ណៈ   ចឹងអត់មានគិតថា  ចាស់ទៅស្រុកកំណើតវិញទេ?

ប៊ុនថូៈ   អត់ទេ  គោលដៅខ្ញុំគិតមុនសង្គ្រាមមកគិតថាមកនៅកន្លែងនេះ ។

វណ្ណៈ   យ៉ាងម៉េចបានជាពូដឹងថាចង់មកនៅហ្នឹង?

ប៊ុនថូៈ   ព្រោះដីវាចង្អេតដូចខ្ញុំថាពីមុនមកចឹង  អ្នកស្រុកមកលេងទីនេះយើងឲ្យលុយទៅវិញ  បើយើងទៅស្រុកលេងវិញទាល់តែមានលុយទាំងទៅទាំងមកវិញ  ព្រោះអីខាងនោះវាចង្អេតក្នុងការរកស៊ី ។

វណ្ណៈ   បាទ ។

ប៊ុនថូៈ   នៅខាងខ្ញុំរបរសំខាន់មានអីមានតែនេសាទហ្នឹង ។

វណ្ណៈ   បាទ!  ខ្ញុំបានមើលឃើញចឹងដែរ   ថាប្រជាជនទៅតាមទីជនបទខ្លះជួបការលំបាក   ទោះបីនៅភ្នំពេញមានភាពរុងរឿងមែន   មានទីផ្សារសេរីមែនតែប្រជាជនមួយចំនួននៅតាមជនបទជួបការលំបាក  ដោយសារគាត់ធ្វើស្រែចំការមិនបាន  ណាមួយគាត់យកលុយធានាគាចឹងទៅ  កាលណាយើងធ្វើខាតនេះហើយជាបញ្ហា ។

ប៊ុនថូៈ   ណាមួយសមត្ថភាពគ្នាវាគ្មាននោះ  ដល់ត្រូវប្រើប្រាស់លុយគណនេយ្យវាល្អិតដល់ចឹងសមត្ថភាពគ្នាមិនមានទៅមិនរួចទេ ។

វណ្ណៈ   ចឹងពូគិតថារស់នៅទឹកដីម៉ាឡៃស្រួលរស់នៅជាង?

ប៊ុនថូៈ   នៅទីនេះស្រួលរស់នៅជាង  មនុស្សល្មមៗអាចរស់នៅបានស្រួល ។

វណ្ណៈ   ចឹងតិចទៀតម៉ាឡៃមានផ្តល់ជាតិទៀត  រឹតតែងាយស្រួលធ្វើដំណើររកស៊ី ។

ប៊ុនថូ: បាទ!នៅនេះអ្នកក្របំផុតអត់មានលុយរកស៊ី គិតថារបរអត់ដើមដើរស៊ីឈ្នួលឲ្យគេបានលុយ ហើយប្តូទៅបេះផ្លែឈើបន្លែយកមកលក់ក៏បានដែរ ។

វណ្ណៈ ចឹងនៅជំនាន់ខ្មែរក្រហមពូគិតថាមានចំនុចអាក្រក់និងចំណុចយ៉ាងម៉េចដែរ?

ប៊ុនថូ: ចំណុចដែលអាក្រក់ដូចខ្ញុំនិយាយមិនឯងការដឹកនាំធ្វើឲ្យមនុស្សស្លាប់ ។

វណ្ណៈ ចឹងចំណុចល្អ?

ប៊ុនថូ: ចំណុចល្អគិតថា នយោបាយដឹកនាំវាល្អ តែការអនុវត្តន៍វាមិនបានត្រឹមត្រូវដូចការលើកឡើង ហ្នឹងវាខុសត្រង់ហ្នឹង ។

វណ្ណៈ បាទ ។

ប៊ុនថូ: ហើយមិនមែនមនុស្សពីរទៅបីនាក់ទៅដឹកនាំប្រទេសបានទេ ព្រោះបេះមានតែពីរបីនាក់ ។

វណ្ណៈ ចឹងពូមានគំនិតចង់ផ្សះផ្សារគ្នារវាងប្រជាជននិងកម្មាភិបាលខ្មែរក្រហមកុំឲ្យមានប្រកាន់គ្នាតទៅ ទៀតពូមានគំនិតផ្សះផ្សារចឹងទេ?

ប៊ុនថូ: បាទ!ចង់ចឹង តែការកាន់គ្នាតាំងពីនៅជំនាន់កុម្មុយនីស្តនោះមិនឲ្យប្រកាន់ទេ ដូចថាខ្មែរគ្នាឯងមក វ៉ៃចឹងចាប់បានមិនឲ្យសម្លាប់ទេ លើកលែងតែយួនទេ ។

វណ្ណៈ បាទ ។

ប៊ុនថូ: អារឿងហ្នឹងមិនឲ្យប្រកាន់តាំងពីហ្នឹងមករហូត ប៉ុន្តែប្រកាន់រឿងមួយដូចជាក្រុមខិលខូចនេះ ដូចថាមានស្លាប់គ្នា ហើយរត់មកពួននៅម៉ាឡៃ កន្លងមកពួនច្រើនដែរ ។

វណ្ណៈ ចឹងពូចង់និយាយឆ្នាំណា?

ប៊ុនថូ: ចង់និយាយពេលយើងផ្តាច់ខ្លួនហើយ ហ្នឹងមានមកបង្កប់ខ្លួនតាមរោងពោតអីហ្នឹង អាហ្នឹងមិនអាចសាមគ្គីជាមួយបានទេ ។

វណ្ណៈ អាហ្នឹងជារឿងក្រោយ រឿងចោររឿងប្លន់ អាហ្នឹងប្រព្រឹត្តិអាក្រក់មានទៅតាមផ្លូវច្បាប់ខ្លះ តាមប្រជាជនកាត់ទោសខ្លះអាហ្នឹងជារឿងធម្មតាទេ ។

ប៊ុនថូ: បាទ ។

វណ្ណៈ ចឹងមុនផ្តាច់ខ្លួនមានបាត់របស់មានចោរទេ?

ប៊ុនថូ: អត់មានទេ ម៉ូតូបញ្ឈរចោលគ្មានពីណាហ៊ានបះផង របស់អ៊ីៗក៏ដោយទុកចោលគ្មានបញ្ហាដូចឥឡូវទេ តែដល់យើងសមាហរណកម្មហើយផ្សារសាច់ឈាមចូលគ្នានេះ ទុករបស់អីប្រហែសមិនបានទេ បាត់ឥឡូវហ្នឹង រោងនៅចំការវិញផ្ទះល្មមៗសុំចាញ់ មានចានឆ្នាំងមានអង្ករមានអំបិលប្រហុកសព្វបែបយ៉ាងសម្រាប់អ្នកដើរដាច់ប៉ែក មិនដែលបាត់ទេ ដល់យើងចូលគ្នាប្របូក

ប្របល់ចូលគ្នាទៅ សូម្បីតែស័ង្កសីក៏វាបកយកទៅលក់ដែរ ឥឡូវនេះទុកអីក៏មិនគង់ទេ សូម្បីប្រទាសអាំងត្រីមិនសល់ផង ។

វណ្ណៈ ចឹងពូខ្ញុំអត់មានអីសួរពូទៀតទេ តើពូមានអ៊ីទៀតចង់និយាយទេ?

ប៊ុនថូៈ អត់ទេ ។

វណ្ណៈ ចឹងខ្ញុំអរគុណច្រើនហើយ ។

**«ចប់»**